# ចម្លាក់មិថុន (Mithuna) នៅក្នុងសិល្បៈខ្មែរសម័យដំបូង

ចម្លាក់មិថុន (Mithuna) សំដៅលើរូបមនុស្សប្រុសនិងមនុស្សស្រីក្នុងទម្រង់សាសង់ស្នេហាគ្នា ដែលគេតាក់តែងឡើងនៅក្នុងគម្ពីររបស់ព្រហ្មញ្ញសាសនា។ ទម្រង់ចម្លាក់នេះ បង្ហាញអំពីគំនិត ដែលបង្ហាញឱ្យឃើញពីរឿងភោគផលដ្បិតមនុស្សប្រុស និងមនុស្សស្រីតែងតែជាគូនឹងគ្នាមិនអាច ខ្វះបានសម្រាប់បង្កើតភោគផល។[១] ចម្លាក់មិថុន (Mithuna) គេប្រទះឃើញដំបូងនៅសម័យសុន្គ (Sunga) នៅរវាងស.វ.ទី២មុនគ្រឹស្តសករាជ (រូបលេខ១) ហើយមានការនិយមខ្លាំងជាបន្តបន្ទាប់នៅក្នុងសិល្បៈឥណ្ឌា (រូបលេខ២)។ មិថុន (Mithuna) មានលក្ខណៈខុសគ្នាខ្លាំងពីចម្លាក់ឥណ្ឌា ដោយម្យ៉ាងទៀតគេហៅថា "មៃថុន" (Maithuna) ដ្បិតចម្លាក់មៃថុនគេសំដៅទៅលើចម្លាក់ដែលបង្ហាញពីភាពស្រើបស្រាលរវាងមនុស្សប្រុស និងមនុស្សស្រីក្នុងការរួមភេទ[២] ដូចមានបង្ហាញឡើងនៅលើចម្លាក់នៅប្រាសាទកាមសូត្រ (Kamasūtra) និងប្រាសាទជាច្រើនទៀតនៅស្រុកឥណ្ឌា ដែលចម្លាក់ភាគច្រើនទាក់ទងនឹងការរួមភេទ (រូបលេខ៣)។

នៅក្នុងសិល្បៈខ្មែរ ចម្លាក់មិថុន (Mithuna) ពុំសូវសម្បូណ៌ឡើយ ពោល គឺមានតិចតួចណាស់នៅសម័យដំបូងៗរបស់ខ្មែរ ដែលជាការទទួលឥទ្ធិពលពីឥណ្ឌាដូចចម្លាក់ផ្សេងៗទៀតដូចគ្នាដែរ។ ប៉ុន្តែចម្លាក់មៃថុន មិនមានឆ្លាក់ឡើយនៅក្នុងសិល្បៈខ្មែរ ដែលទំនងមកពីចម្លាក់នេះមានភាពស្រើបស្រាលពេក ខ្មែរបុរាណមិនហ៊ានទទួលយក។

គេបានប្រទះឃើញចម្លាក់មិថុន (Mithuna) ដំបូងនៅអូរកែវ ដែលធ្វើអំពីដុត និងសព្វថ្ងៃរក្សាទុកនៅសារមន្ទីរខេត្តអានយ៉ាង ប្រទេសវៀតណាម (រូបលេខ៤)។[៣] ចម្លាក់នេះឆ្លាក់នៅក្នុងក្បាច់រាងដូចក្រចកសេះ ដែលគេហៅថា "គូឌុ" បង្ហាញអំពីមនុស្សប្រុសនិងមនុស្សស្រីត្រឹមពាក់កណ្តាលខ្លួន ដែលខាងប្រុសយកដៃម្ខាងទ្រដើមទ្រូងមនុស្សស្រី។ ចម្លាក់ដីដុតនេះ អាចស្ថិតនៅក្នុងសម័យហ្វូណន រវាងស.វ.ទី៣ដល់ទី៥ នៃគ្រឹស្តសករាជ ប្រហាក់ប្រហែលនឹងចម្លាក់គូឌុធ្វើអំពីដីដុតផ្សេងទៀតដែលអ្នកស្រាវជ្រាវ Louis Malleret រកឃើញដែរ។[៤]

ចម្លាក់មិថុនមួយទៀតដែលយើងគិតថាសំខាន់នោះ គឺរកឃើញនៅផ្នែកកំពូលនៃប្រាសាទយាយព័ន្ធ តួប៉មកណ្តាល S1 (រូបលេខ៥) ដែលជាចម្លាក់នៅលើឥដ្ឋ បង្ហាញពីរូបមនុស្សប្រុសម្នាក់

---

[១] Agrawala 1983.

[២] Gordon 2003: 81-85.

[៣] Le 2006: 115.

[៤] Malerret 1959: 297.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

យកដៃម្ខាងឱបពីក្រោយមនុស្សស្រីម្នាក់ត្រឹមស្មា ហើយរូបនេះគេបង្ហាញត្រឹមមួយកំណាត់ខ្លួនដូចរូបធ្លាក់ពីដីដុតរកឃើញនៅកំពង់ផែអូរកែវដែរ។ នៅក្នុងការសិក្សារបស់លោក Victorio Roveda លោកមិនបានលម្អិតអំពីចម្លាក់នេះឡើយ ដោយគ្រាន់តែសន្និដ្ឋាន ទំនងជាគូស្នេហ៍ ឬអាចមនុស្សប្រុសកំពុងធ្វើបានមនុស្សស្រី។[៥]

ចម្លាក់មៃថុនចុងក្រោយដែលរកឃើញនៅសិល្បៈខ្មែរ យើងប្រទះឃើញនៅផ្នែកខាងលើប្រាសាទភ្នំបាយ៉ង់ ដែលជាប្រាសាទសាងសង់នៅស.វ.ទី៧ ប្រហាក់ប្រហែលប្រាសាទយាយព័ន្ធដែរ។ ប៉ុន្តែចម្លាក់ដែលយើងឃើញ គឺបង្ហាញពីមនុស្សប្រុសនិងមនុស្សស្រីដេកក្បែរគ្នា ហើយដាក់ក្បាលទៅទិសផ្សេងគ្នាទៀតផង (រូបលេខ២៦)។

ជារួមមក ការបង្ហាញចម្លាក់មៃថុននៅក្នុងសិល្បៈខ្មែរ ចំនួន ៣ ខាងលើនេះ គ្រាន់តែចង់បង្ហាញថា ឥទ្ធិពលឥណ្ឌាមកលើសង្គមខ្មែរនៅពេលនោះមានទំហំខ្លាំងក្លាណាស់ ម្ល៉ោះហើយគំនិតនៃចម្លាក់ភោគផលដែលឥណ្ឌាមាន ខ្មែរក៏បានយកមកឆ្លាក់នៅលើសំណង់ប្រាសាទខ្មែរដូចគ្នាដែរ។

## ឯកសារយោង

**David, Gordun**
2003, *Kiss of the Yogini: 'Trantric sex' in its South Asian context*, University of Chicago

**Louis Malleret**
1959, L'archéologie du delta du Mékong, *BEFEO*, Tome 43, Paris

**Prithvi K., Agrawala**
1983, *Mithuna, The male-female symbol in Indian arts and though*, Munsiram Manoharlal Publishers PVT. LTD

**Roveda, Victorio**
2005, "*Image of the gods*", Bangkok

KHMER CIVILIZATION

[៥] Roveda 2005.





រូបលេខ២១-២៖ ចម្លាក់មិថុននៅស្រុកឥណ្ឌា (រូបថត៖ Heater Elgood)



រូបលេខ២៣៖ ចម្លាក់មៃថុននៅស្រុកឥណ្ឌា

(ប្រភព៖ Heater Elgood)



រូបលេខ២៤៖ ចម្លាក់មិថុនធ្វើពីដីដុត រកឃើញ

នៅកំពង់ផែអូកែវ (ប្រភព៖ Le 2006)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៥៖ ចម្លាក់មិថុននៅប្រាសាទយាយព័ន្ធ (រូបថត៖ កុំ រតនៈពិសិដ្ឋ)



រូបលេខ៦៖ ចម្លាក់មិថុននៅប្រាសាទភ្នំបាយ៉ង់ (រូបថត៖ លាក់ ស៊ីផាន់ណា)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី